ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ២៣/០៩ ប.ស.ស

# សេចក្ដីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គម មានកិត្តិយសសូមជម្រាបជូនកម្មករនិយោជិតដែលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គមមេត្តាជ្រាបថា កន្លងមកមានកម្មករនិយោជិតមួយចំនួនទទួល *រងគ្រោះថ្នាក់ការងារហេតុដល់បាត់បង់ជីវិត* ហើយឧត្តរជីវី (*អ្នកនៅក្នុងបន្ទុកផ្ទាល់ដែលជា ប្ដី ឬ ប្រពន្ធ និងកូន*) មិនរពចហានសិទ្ធិទទួលបានតាវកាលិក(អត្ថប្រយោជន៍)ឧត្តរជីវី ពីបេឡាជាតិរបបសន្តិសុខសង្គម។ ការមិនទទួលបាននេះ ដោយសារជនរងគ្រោះ*មិនមានសំបុត្រអាពាហ៍ពិពាហ៍* ដែលជាហេតុបណ្ដាលឲ្យអ្នកនៅក្នុងបន្ទុកទាំងនោះពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមច្បាប់ដើម្បីទទួលបានតាវកាលិក(អត្ថប្រយោជន៍)។ ករណីបែបនេះ បេឡាជាតិរបបសន្តិសុខសង្គមមានការសោកស្ដាយយ៉ាងខ្លាំង ដែលមិនអាចផ្ដល់តាវកាលិកជូនដល់ក្រុមគ្រួសារជនរងគ្រោះដែល*គ្មានសំបុត្រអាពាហ៍ពិពាហ៍*បាន។

ដូចនេះ បេឡាជាតិរបបសន្តិសុខសង្គម សំណូមពរដល់បងប្អូន*កម្មករនិយោជិត ព្រមទាំងឧត្តរជីវី* (អ្នកនៅក្នុងបន្ទុកផ្ទាល់) របស់ខ្លួនទាំងអស់ ត្រូវមានឯកសារចាំបាច់ដូចខាងក្រោម៖

១. សំបុត្រអាពាហ៍ពិពាហ៍ (ចាំបាច់សម្រាប់អ្នកមានគូស្រករ)

២. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

៣. សំបុត្រកំណើត

ដើម្បីចៀសវាងការបាត់បង់ផលប្រយោជន៍ដ៏ច្រើននេះ បេឡាជាតិរបបសន្តិសុខសង្គមសូមរំពាវនាវ ដល់លោក លោកស្រី ជានិយោជក ឬ នាយក សហគ្រាស គ្រឹះស្ថានទាំងអស់ មេត្តាផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់កម្មករនិយោជិតរបស់ខ្លួន តាមគ្រប់លទ្ធភាពដែលអាចធ្វើបាន។

បេឡាជាតិរបបសន្តិសុខសង្គមមានសេចក្ដីសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី និយោជក ឬ នាយកសហគ្រាស គ្រឹះស្ថាន ព្រមទាំងបងប្អូនកម្មករនិយោជិតទាំងអស់ចូលរួម សហការអនុវត្តសេចក្ដីជូនដំណឹងនេះ ដើម្បីរួមចំណែកការពារសិទ្ធិស្របច្បាប់នៃអ្នកនៅក្នុងបន្ទុករបស់ជនរងគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩

នាយក

អ៊ុក សមវិទ្យា